ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧
# និងទិសដៅការងារឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ខេត្រកំពង់ចាម ថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨

សូមគោរព៖

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព និងស្និទ្ធស្នាលជាទីបំផុតក្នុងនាមជាសមាជិកគ្រួសារធនាគារជាតិនៃកម្ពុជាតែមួយ។ ខ្ញុំសូមវាយតម្លៃខ្ពស់និងអបអរសាទរចំពោះលទ្ធផលដែលយើងសម្រេចបាន នៅឆ្នាំ២០១៧ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកយើងទាំងអស់គ្នាក្នុងការរួមចំណែកកសាងសមិទ្ធផលដ៏ល្អប្រសើរនេះ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានផ្តល់បទអន្តរាគមន៍និងធ្វើបទបង្ហាញជូនអង្គសន្និបាតយើង។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិក-សមាជិកាអង្គសន្និបាតទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងអង្គ-សន្និបាត និងយកចិត្តទុកដាក់ត្រងត្រាប់ស្តាប់ខ្លឹមសារសំខាន់ៗនៃអង្គសន្និបាត ក្នុងរយៈពេលមួយថ្ងៃកន្លះនេះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សមិទ្ធផលការងារ ដែលយើងសម្រេចបានពិតជាបានរួមចំណែកដល់ការពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ចំពោះទស្សនវិស័យនៅឆ្នាំ២០១៨នេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថាសេដ្ឋកិច្ចពិភពលោកនឹងតំបន់បន្តមានស្ថានភាពល្អប្រសើរ និងរក្សាបានកំណើនប្រហាក់ប្រហែលនឹងឆ្នាំ២០១៧។ ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជានឹងបន្តទទួលបានអំណោយផល ហើយរំពឹងថានឹងមានកំណើនប្រមាណ ៦,៩% ដូចឆ្នាំ២០១៧ដែរ ទោះបីជាមានបញ្ហាប្រឈមមួយចំនួនក៏ដោយ។ កំណើនរឹងមាំនឹងត្រូវបានគាំទ្រដោយការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុល្អប្រសើរ។ អត្រាអតិផរណាជាមធ្យមប្រចាំឆ្នាំ២០១៨ ត្រូវបានព្យាករថានឹងបន្តមានកម្រិតទាបអាចគ្រប់គ្រងបានប្រមាណ ៣% ហើយអត្រាប្តូរប្រាក់នឹងរក្សាបានស្ថិរភាពជាមធ្យមប្រមាណ ៤.០៣៧ រៀលក្នុងមួយដុល្លារអាមេរិក។ ទន្ទឹមនេះវិស័យធនាគារនឹងបន្តរីកចម្រើនប្រកបដោយបរិយាប័ន្ន និងផ្តល់សេវាហិរញ្ញវត្ថុដល់វិស័យចម្បងៗនៃសេដ្ឋកិច្ច ជាពិសេស កំណើនឥណទានទៅកាន់វិស័យឯកជនរំពឹងថានឹងមានកំណើនក្នុងកម្រិតសមស្របប្រហាក់ប្រហែលនឹងឆ្នាំ២០១៧។

ដើម្បីរួមចំណែកសម្រេចឱ្យបានតាមគោលដៅខាងលើ ធនាគារជាតិនៃកម្ពុជានឹងបន្តរក្សាស្ថិរភាពថ្លៃ ជំរុញភាពស៊ីជម្រៅនិងបរិយាប័ន្នហិរញ្ញវត្ថុ ពង្រឹងស្ថិរភាពហិរញ្ញវត្ថុ បង្កើនសមាហរណកម្មវិស័យហិរញ្ញវត្ថុទៅក្នុងតំបន់ និងអនុវត្តគោលនយោបាយរូបិយវត្ថុស្របតាមក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។

ក្នុងទិសដៅនេះ ខ្ញុំសូមផ្ដាំផ្ញើដល់អង្គសន្និបាតនូវការងារចម្បងៗដែលយើងត្រូវអនុវត្ត បន្តក្នុងឆ្នាំ២០១៨នេះដូចតទៅ ៖

១/- ខ្ញុំសូមគាំទ្រនូវការលើកឡើងរបស់ អគ្គនាយកដ្ឋានបច្ចេកទេស លើការបន្តអនុវត្ត គោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពប្រុងប្រយ័ត្ននិងបត់បែន សំដៅជំរុញកំណើន សកម្មភាពសេដ្ឋកិច្ច។ ក្នុងន័យនេះ ការរក្សាស្ថិរភាពអត្រាប្ដូរប្រាក់នៅតែជាជម្រើស គោលនយោបាយសមស្របសម្រាប់រក្សាស្ថិរភាពថ្លៃ ហើយការអភិវឌ្ឍឧបករណ៍គោល-នយោបាយរូបិយវត្ថុ ក៏ដូចជាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនឹងបន្តធ្វើឡើងជា លំដាប់ផ្អែកតាមយន្តការទីផ្សារ។ ម្យ៉ាងទៀត ប្រព័ន្ធទូទាត់នឹងត្រូវធ្វើទំនើបកម្មស្របតាមការ រីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប៉ុន្តែក៏ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ននិងពង្រឹងយន្តការ ការពារហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ ដូចជា ឧក្រិដ្ឋកម្មបច្ចេកវិទ្យាជាដើម នៅក្នុងយុគសម័យបច្ចេកវិទ្យាទំនើបនេះ។

២/- ខ្ញុំសូមឯកភាពតាមមតិរបស់ ឯកឧត្តម អគ្គបេឡា ដែលលើកឡើងថា យើង ត្រូវបន្តពង្រឹងសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិ ការដឹកជញ្ជូនធនបត្រ និងគុណភាពនៃការ ផ្ដល់សេវាជូនអតិថិជន។ កន្លងមក ការងារនេះយើងបានអនុវត្តប្រកបដោយប្រសិទ្ធភាព ព្រមទាំងបានរួមចំណែកពង្រឹងការប្រើប្រាស់ប្រាក់រៀល និងសម្រួលដល់លំហូរសាច់ប្រាក់ ក្នុងប្រព័ន្ធធនាគារសម្រាប់គាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច។ ទន្ទឹមនេះ ខ្ញុំសូមស្នើឱ្យ អគ្គបេឡាបន្តយុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែសកម្មថែមទៀត។

ចំពោះការពង្រឹងវិន័យការងារនិងបទបញ្ជាផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ខ្ញុំសូម ឯកភាពតាម ឯកឧត្តម ប្រធានក្រុមប្រឹក្សាវិន័យ ដែលបានលើកឡើងថា យើងត្រូវតែរួមគ្នា សហការពង្រឹងវិន័យនិងបទបញ្ជាផ្ទៃក្នុង ដើម្បីលើកកម្ពស់ថែមទៀតនូវប្រសិទ្ធភាពការងារ ស្នូល។ ជាមួយគ្នានេះ ខ្ញុំសូមគាំទ្រចំពោះវិធានការដែលបានលើកឡើងពីចំណុចអសកម្ម

របស់មន្ត្រី-បុគ្គលិកមួយចំនួន ដែលកើតមានក្នុងពេលបំពេញការងារ ជាពិសេស ការមកធ្វើការយឺត, ការខ្វះកិច្ចសហការការងារជាមួយនឹងសហការី, ការខ្វះឆន្ទៈក្នុងការបំពេញការងារ, ការមិនគោរពវិន័យនិងភារកិច្ច ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងាររបស់ខ្លួន ព្រមទាំងរបស់នាយកដ្ឋាន-អង្គភាព និងស្ថាប័នថែមទៀតផង។

៣/- ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍធនធានមនុស្ស ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដូចដែល ឯកឧត្តម ទេសាភិបាលរង បានលើកឡើង។ ខ្ញុំសូមឯកភាពលើមតិរបស់ ឯកឧត្តម ទេសាភិបាលរង ដែលលើកឡើងថា "ធនធានមនុស្សគឺជាទ្រព្យសកម្មដ៏សំខាន់និងចាំបាច់សម្រាប់ការអភិវឌ្ឍរីកចម្រើនទាំងចំពោះស្ថាប័នសាធារណៈនិងឯកជន" និងការលើកឡើងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកដែលថា "Invest more and more effectively, in people ជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍" ។ យើងបានធ្វើការបណ្តុះបណ្តាលមន្ត្រី-បុគ្គលិក តាមរយៈការសិក្សាទាំងក្នុងប្រទេសនិងក្រៅប្រទេសរយៈពេលខ្លីនិងរយៈពេលវែង ព្រមទាំងលើកទឹកចិត្តឱ្យខិតខំពង្រឹងចំណេះដឹងនិងជំនាញ ដែលការងារនេះត្រូវបន្តធ្វើបន្ថែមទៀត ដើម្បីបណ្តុះបណ្តាលកម្លាំងបន្តវេនប្រកបដោយគុណវុឌ្ឍិនិងស្មារតីទទួលខុសត្រូវ។ ដូច្នេះ ខ្ញុំសូមឯកភាពលើផែនការដែលបានលើកឡើងក្នុងការបណ្តុះបណ្តាលធនធានមនុស្សនិងស្នើឱ្យ ឯកឧត្តម ទេសាភិបាលរង និង ឯកឧត្តម អគ្គលេខាធិការ បន្តរៀបចំវគ្គបណ្តុះបណ្តាលជំនាញ ស្របតាមការរីកចម្រើននៃវិស័យធនាគារ និងសមាហរណកម្មក្នុងតំបន់។

៤/- ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះរបាយការណ៍របស់ ឯកឧត្តម អគ្គលេខាធិការ ដែលលើកឡើងអំពីបច្ចុប្បន្នភាពនៃសៀវភៅក្រហម និងប្រព័ន្ធធនាគារស្នូល Flexcube របស់ធនាគារជាតិនៃកម្ពុជា។ ខ្ញុំក៏សូមគាំទ្រចំពោះការលើកឡើងថា ការធ្វើបច្ចុប្បន្នកម្មសៀវភៅក្រហម និងប្រព័ន្ធធនាគារស្នូល Flexcube ពិតជាបានជួយពង្រឹងគុណភាពការងារឱ្យ

កាន់តែឆាប់រហ័ស និងមានសុក្រឹតភាពបន្ថែមទៀត ស្របតាមទំហំប្រតិបត្តិការរបស់ធនាគារកណ្តាល។ ទន្ទឹមនេះ ខ្ញុំសូមឯកភាពចំពោះសំណូមពររបស់ ឯកឧត្តម អគ្គលេខាធិការ ដែលបានស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជាខិតខំថែរក្សាបណ្ណាល័យ និងលើកទឹកចិត្តមន្ត្រី-បុគ្គលិកឱ្យសិក្សាស្រាវជ្រាវបន្ថែម។

ខ្ញុំពិនិត្យឃើញថា ទំហំការងាររបស់យើងកាន់តែកើនឡើងជាលំដាប់នៅតាមបណ្តាសាខារាជធានី-ខេត្ត ដោយសារការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចនៅទូទាំងប្រទេស និងកំណើនជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារ។ ដូច្នេះ ដើម្បីបន្តពង្រឹងសេវាធនាគារកណ្តាលឱ្យកាន់តែមានប្រសិទ្ធភាព ខ្ញុំស្នើសូមឱ្យសាខារាជធានី-ខេត្តទាំងអស់បន្តសម្រួលចរាចរណ៍សាច់ប្រាក់ដើម្បីបំពេញសេចក្តីត្រូវការនៅតាមតំបន់របស់ខ្លួន និងបន្តកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័ន-មន្ទីរនានា ជាពិសេសក្នុងដំណើរនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

៥/- ខ្ញុំសូមគាំទ្រការលើកឡើងរបស់ ឯកឧត្តម អគ្គនាយកត្រួតពិនិត្យ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងវិស័យធនាគារ ជាពិសេសក្នុងស្ថានភាពដែលវិស័យធនាគារមានការរីកចម្រើននិងសមាហរណកម្មយ៉ាងឆាប់រហ័សទៅក្នុងតំបន់។ ដើម្បីបន្តធ្វើឱ្យវិស័យធនាគារដើរតួនាទីស្នូលក្នុងខឿនសេដ្ឋកិច្ច ខ្ញុំសូមឱ្យអគ្គនាយកដ្ឋានត្រួតពិនិត្យ លើកកម្ពស់យន្តការត្រួតពិនិត្យនិងបទប្បញ្ញត្តិ ផ្អែកតាមមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ព្រមទាំងបន្តពង្រឹងប្រសិទ្ធភាពនៃអន្តរការិយកម្មហិរញ្ញវត្ថុ។ ម្យ៉ាងទៀតខ្ញុំក៏សូមឱ្យបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដោយគិតគូរពីការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។ ក្នុងទិសដៅនេះ អគ្គនាយក-ដ្ឋានត្រួតពិនិត្យ ត្រូវបញ្ចប់ការរៀបចំយុទ្ធសាស្ត្រស្តីពីបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់កម្ពុជា ពង្រឹងកិច្ចគាំពារអតិថិជន លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន និងអភិវឌ្ឍបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុនានា ដូចជា ការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ។

ទន្ទឹមនេះ សូមអគ្គនាយកដ្ឋានត្រួតពិនិត្យបន្តយុទ្ធនាការចុះនៅតាមមូលដ្ឋាន ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីការប្រើប្រាស់សេវាហិរញ្ញវត្ថុនិងវិស័យមីក្រូហិរញ្ញវត្ថុ ព្រមទាំងបន្តពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធទូរស័ព្ទ Hotline នៅគ្រប់រាជធានី-ខេត្ត ដើម្បីឆ្លើយតបនឹងសំណួរនានារបស់សាធារណជនពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ខ្ញុំក៏សូមឱ្យពង្រឹងការតាមដាននិងវាយតម្លៃហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញនូវគោលនយោបាយមីក្រូនិងម៉ាក្រូប្រុង-ប្រយ័ត្នប្រកបដោយប្រសិទ្ធភាព។

៦/- ខ្ញុំសូមឯកភាពតាមសំណូមពរដែលបានលើកឡើងដោយ លោកជំទាវ អគ្គពិនិត្យ ដើម្បីពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដែលជាការងារស្នូលរបស់យើងក្នុងការពង្រឹងសុវត្ថិភាពនិងប្រសិទ្ធភាពប្រតិបត្តិការធនាគារកណ្តាល។ ទន្ទឹមនេះ ខ្ញុំសូមស្នើសុំឱ្យអគ្គាធិការដ្ឋានបន្តពង្រឹង និងបង្កើនការយល់ដឹងអំពីការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងតាមដានការអនុវត្តតាមអនុសាសន៍ចំពោះនាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជាដែលបានធ្វើសវនកម្មរួចហើយ។

៧/- ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងាររបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ហានិភ័យកម្រិតទាបលើការផ្តល់ហិរញ្ញប្បទានភេរវកម្ម និងរួមចំណែកពង្រឹងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ ខ្ញុំសូមស្នើឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបន្តពង្រឹងយន្តការតាមដាននិងការវិភាគប្រតិបត្តិការសង្ស័យ បន្តពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុងនិងក្រៅប្រទេស និងបន្តតាមដានការអនុវត្តតាមអនុសាសន៍វាយតម្លៃអញ្ញមញ្ញរបស់ APG។

៨/- ពាក់ព័ន្ធនឹងការងារសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា នាឆ្នាំនេះ យើងមានឱកាសរៀបចំមហាសន្និបាតសមាគមនិងបានបោះឆ្នោតជ្រើសរើសសមាជិកគណកម្មាធិការសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា (ស.ម.ធ) សម្រាប់អាណត្តិទី៧ ហើយ ខ្ញុំសូមចូលរួមអបអរសាទរចំពោះសមាសភាពថ្នាក់ដឹកនាំសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាដែលបន្តអាណត្តិ២ឆ្នាំថែមទៀត។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលរបស់សមាគមដែលបានរួមចំណែកសម្រាលទុក្ខលំបាករបស់សមាជិក និងគ្រួសារសមាជិកនារយៈពេលកន្លងមក។ ជាមួយគ្នានេះ ខ្ញុំសូមស្នើសុំឱ្យសមាគមធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការផ្តល់ប្រាក់ឧបត្ថម្ភដល់សមាជិកឱ្យកាន់តែច្បាស់ ដើម្បីបន្តពង្រឹងការគ្រប់គ្រងនិងការប្រើប្រាស់មូលនិធិរបស់សមាគមឱ្យបានត្រឹមត្រូវ ប្រកបដោយយុត្តិធម៌និងសមធម៌។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំជឿជាក់ថាសមាជិក-សមាជិកា អង្គសន្និបាតរបស់យើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃសមិទ្ធផលការងារ និងទិសដៅដែលបានលើកឡើងក្នុងអង្គសន្និបាត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកយកទស្សនៈមួយរបស់ទស្សនវិទូចិនខុងជឺដែលពោលថា "មនុស្សសាមញ្ញអាចក្លាយជាមនុស្សពូកែ តាមរយៈភាពឧស្សាហ៍ព្យាយាម ឯមនុស្សពូកែនឹងក្លាយជាមនុស្សសាមញ្ញដោយសារភាពខ្ជិល"។ ដូច្នេះ យើងគួរតែប្បីធ្វើការងារប្រកបដោយភាពនឹងធឹង បង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំមួយ ព្រមទាំងខិតខំប្រឹងប្រែងបំពេញការងារជាប្រចាំ។ ទន្ទឹមនេះ លោក ឆៃ យាន់តែ ដែលជាអ្នកអប់រំនិងអ្នកវិទ្យាសាស្ត្រចិនមួយរូបមានប្រសាសន៍ថា យើងត្រូវប្រកាន់ខ្ជាប់សីលធម៌និងគុណធម៌ ដោយសារគុណធម៌គឺជាមូលដ្ឋាននិងជាឫសគល់សម្រាប់បុគ្គលនិងសង្គមជាតិ ហើយការបណ្តុះសីលធម៌នេះជាអាទិភាពក្នុងការប្រកបកិច្ចការងារ ចំណែកឯការស្គាល់គុណធម៌អាចញ៉ាំងឱ្យបុគ្គលសម្រេចបានគោលដៅដ៏ឧត្តុង្គឧត្តម។ បុគ្គលមួយរូបអាចត្រូវបានផ្តល់មុខដំណែង

មួយដ៏ត្រឹមត្រូវ លុះត្រាតែបុគ្គលនោះស្គាល់គុណធម៌ ដើរតាមក្រមសីលធម៌សង្គម ព្រមទាំងដាក់កំហិតចំណង់របស់ខ្លួន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីសម្រេចបាននូវជោគជ័យថ្មីៗតាមទិសដៅដែលបានកំណត់ ខ្ញុំសូមស្នើឱ្យថ្នាក់ដឹកនាំតាមនាយកដ្ឋាន-អង្គភាពទាំងអស់ ត្រូវយកស្មារតីនេះទៅផ្សព្វផ្សាយបន្តដល់មន្ត្រី-បុគ្គលិករបស់ខ្លួន ដើម្បីឱ្យការអនុវត្តការងារប្រចាំថ្ងៃប្រព្រឹត្តទៅដោយរលូន និងសូមឱ្យមន្ត្រី-បុគ្គលិកយើងបន្តស្មារតីរួមសាមគ្គីសហការគ្នាជាប្រពៃណី និងការទទួលខុសត្រូវខ្ពស់ចំពោះការងារ សំដៅរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបានសមិទ្ធផលថ្មីៗនិងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

ដូចអង្គសន្និបាតបានជ្រាបរួចហើយថា ធនាគារជាតិនៃកម្ពុជានឹងចាប់ផ្តើមសាងសង់អគារស្នាក់ការកណ្តាលថ្មីលើទីតាំងចាស់នៅក្នុងឆ្នាំនេះ ស្របតាមកំណើនមន្ត្រី-បុគ្គលិក និង ការរីកចម្រើនវិស័យធនាគារបង្ហាញពីភាពរឹងមាំរបស់ប្រព័ន្ធធនាគារ ព្រមទាំងលើកសោភ័ណភាពរាជធានីភ្នំពេញ។ ក្នុងរយៈពេលសាងសង់នេះ មន្ត្រី-បុគ្គលិកដែលនៅទីស្នាក់ការកណ្តាលលើកលែងតែបញ្ជរបេឡា នឹងធ្វើការបណ្តោះអាសន្ននៅអគារក្បែរអគាររោងពុម្ពនៅលើផ្លូវ១០១៩ ខណ្ឌសែនសុខ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាត និងក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២០១៨នេះ ខ្ញុំសូមជូនពរដល់សមាជិក-សមាជិកាទាំងអស់មានសុខភាពល្អ ទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ!**

**សូមអរគុណ!**